ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែប
ប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ (គ.ជ.អ.ប)
លេខាធិការដ្ឋាន

លេខ.០១០...[illegible]./គ.ជ.អ.ប

រាជធានីភ្នំពេញ, ថ្ងៃទី..១០.. ខែ..[illegible].. ឆ្នាំ២០១០

## សូមជម្រាបជូន

## ឯកឧត្តមអភិបាល និងជាប្រធានគណៈកម្មាធិការប្រតិបត្តិរាជធានី ខេត្ត

**កម្មវត្ថុ:** ការកំណត់អត្រាប្រាក់ឧបត្ថម្ភបេសកកម្ម សម្រាប់ប្រើប្រាស់នៅក្នុងក្របខ័ណ្ឌគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ។

**យោង:** -អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកំណត់ប្រាក់របបបេសកកម្មក្នុង និងក្រៅប្រទេស

-សេចក្តីសម្រេចលេខ២០០០ សហវ.វស ចុះថ្ងៃទី២៣ ខែមេសា ឆ្នាំ២០០៧ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការកំណត់ប្រាក់ឧបត្ថម្ភ និងប្រាក់របបបេសកកម្មក្រោមក្របខ័ណ្ឌគម្រោងហិរញ្ញប្បទានដោយធនាគារអភិវឌ្ឍន៍អាស៊ី និងធនាគារពិភពលោក

-យោបល់ឯកភាពរបស់ឯកឧត្តមឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.អ.ប

-តម្រូវការចាំបាច់របស់ គ.ជ.អ.ប

តបតាមខ្លឹមសារក្នុងកម្មវត្ថុនិងយោងខាងលើ ខ្ញុំមានកិត្តិយសសូមជម្រាបជូនឯកឧត្តមមេត្តាជ្រាបថា បច្ចុប្បន្នមានគម្រោងជាច្រើនដែលស្ថិតក្រោមក្របខ័ណ្ឌគ្រប់គ្រងរបស់ គ.ជ.អ.ប ដែលគាំទ្រមូលនិធិដោយគម្រោង និងកម្មវិធីផ្សេងៗទៀតដូចជា គម្រោង UNDP/PSDD គម្រោង RILGP/WB កម្មវិធី NRM&L/DANIDA និងគម្រោង RPRP/IFAD ជាដើម ។ គម្រោង និងកម្មវិធីមួយចំនួនឯកភាពលើការអនុវត្តតាមសេចក្តីសម្រេចលេខ ២០០០ សហវ.វស ចំណែកគម្រោង និងកម្មវិធីមួយចំនួនទៀតឯកភាពលើការប្រើប្រាស់អនុក្រឹត្យលេខ១០ អនក្រ.បក ចុះថ្ងៃទី១២ ខែមេសា ឆ្នាំ២០០៤ របស់រាជរដ្ឋាភិបាលកម្ពុជាស្តីពីការកំណត់ប្រាក់ឧបត្ថម្ភបេសកកម្មក្នុង និងក្រៅប្រទេស ។ បញ្ហានេះ បាននាំឱ្យមានភាពយឺតយ៉ាវ និងរាំងស្ទះដល់ការអនុវត្តសកម្មភាពរបស់គម្រោង និងកម្មវិធីនានាទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ជាពិសេសកិច្ចការចាំបាច់នានានៅក្នុងឆ្នាំ២០១០ ដែលជាឆ្នាំអន្តរកាលដ៏សំខាន់មួយ ។

ដូច្នេះ ដើម្បីដោះស្រាយនូវបញ្ហានេះ និងធានាបាននូវការឯកភាពពីដៃគូអភិវឌ្ឍន៍នានាដែលបាន និងកំពុងគាំទ្រមូលនិធិដល់គម្រោង និងកម្មវិធីនានាដែលគ្រប់គ្រងដោយ គ.ជ.អ.ប និងដើម្បីឱ្យមានសង្គតិភាពរវាងសេចក្តីសម្រេចលេខ២០០០ សហវ.វស និងអនុក្រឹត្យលេខ១០ អនក្រ.បក លេខាធិការដ្ឋាន គ.ជ.អ.ប បានសម្រេចកំណត់អត្រាប្រាក់ឧបត្ថម្ភបេសកកម្ម គាំទ្រដំណើរការប្រតិបត្តិការប្រចាំថ្ងៃរបស់ គ.ប្រ រាជធានី ខេត្ត ដូចខាងក្រោម :

**ក.** ប្រាក់របបពិសេសសម្រាប់មន្ត្រីជាន់ខ្ពស់មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការ អគ្គនាយក ឬមន្ត្រីថ្នាក់ស្មើនឹងមុខតំណែងនេះឡើងទៅ :

| **សោហ៊ុយចំណាយបេសកកម្ម** | **របបឧបត្ថម្ភក្នុងម្នាក់/ថ្ងៃឬយប់** | **ផ្សេងៗ** |
|---|---|---|
| ប្រាក់ហោប៉ៅ | ១៦.០០០ ៛ | * នៅក្នុងរាជធានីភ្នំពេញ ឬក្នុងទីរួមខេត្តតាមខេត្តនានាមិនផ្តល់ជូនទេ។ |
| ប្រាក់ហូបចុក | ៣០.០០០ ៛ | * បេសកកម្មរយៈពេលខ្លី : ធ្វើដំណើរដោយមធ្យោបាយរបស់រដ្ឋ និងមិនសំរាកពេលយប់ ផ្តល់ជូនតែប្រាក់ហោប៉ៅ និងប្រាក់ហូបចុកតែប៉ុណ្ណោះ។ |
| ប្រាក់ស្នាក់នៅ | ៨០.០០០ ៛ | |
| **សរុប (៛)** | **១២៦.០០០ ៛** | |

**ខ.** ប្រាក់របបបេសកកម្មសម្រាប់មន្ត្រីរាជការទូទៅ មានឋានៈចាប់ពីថ្នាក់អគ្គលេខាធិការរង អគ្គនាយករង ឬមន្ត្រីថ្នាក់ស្មើនឹងមុខតំណែងនេះ ចុះក្រោម :

| សោហ៊ុយចំណាយបេសកកម្ម | **របបឧបត្ថម្ភក្នុងម្នាក់/ថ្ងៃ ឬយប់** | | | | | | | រយៈពេល |
|---|---|---|---|---|---|---|---|---|
| | ក្នុងរាជធានីភ្នំពេញ ឬក្នុងទីរួមខេត្តតាមខេត្តនានា | សម្រាប់ក្នុងទឹកដីរាជធានី ខេត្ត ដែលមានចំងាយផ្លូវ | | សម្រាប់ក្នុងទឹកដីភូមិភាគឮសានដែលមានចំងាយផ្លូវ | | បេសកកម្មឆ្លងរាជធានី ខេត្ត ដែលមានចំងាយផ្លូវ | | |
| | | **ពី១០ ដល់ ៤០គ.ម** | **លើសពី ៤០គ.ម** | **ពី៥ ដល់ ៣០គ.ម** | **លើសពី ៣០គ.ម** | **ពី១០ ដល់ ៤០គ.ម** | **លើសពី ៤០គ.ម** | |
| -ប្រាក់ហោប៉ៅ | មិនផ្តល់ជូនទេ | ៨.០០០ ៛ | ៨.០០០ ៛ | ៨.០០០ ៛ | ៨.០០០ ៛ | ៨.០០០ ៛ | ៨.០០០ ៛ | ០១ ថ្ងៃ |
| -ប្រាក់ហូបចុក | -ដ- | ១៥.០០០ ៛ | ១៥.០០០ ៛ | ១៥.០០០ ៛ | ១៥.០០០ ៛ | ១៥.០០០ ៛ | ១៥.០០០ ៛ | ០១ ថ្ងៃ |
| -ប្រាក់ស្នាក់នៅ | -ដ- | មិនផ្តល់ជូនទេ | ៤០.០០០ ៛ | មិនផ្តល់ជូនទេ | ៤០.០០០ ៛ | មិនផ្តល់ជូនទេ | ៤០.០០០ ៛ | ០១ យប់ |
| **សរុប (៛)** | ០ ៛ ០០ | **២៣.០០០ ៛** | **៦៣.០០០ ៛** | **២៣.០០០ ៛** | **៦៣.០០០ ៛** | **២៣.០០០ ៛** | **៦៣.០០០ ៛** | |

*** ចំពោះសោហ៊ុយធ្វើដំណើរ ការទូទាត់ត្រូវធ្វើឡើងដោយផ្អែកតាមតម្លៃក្នុងវិក័យប័ត្រជាក់ស្តែង (ក្នុងករណីការធ្វើដំណើរមិនមែនដោយមធ្យោបាយរបស់រដ្ឋ ឬគម្រោង)។

លេខាធិការដ្ឋាន គ.ជ.អ.ប សូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ និងកោតសរសើរដោយស្មោះចំពោះឯកឧត្តម ដែលបានធានានិរន្តភាពការងាររបស់ គ.ប្រ ក្នុងដំណាក់កាលឆ្លងកាត់ដ៏លំបាកនេះ។

អាស្រ័យហេតុដូចបានជម្រាបជូនខាងលើ សូមឯកឧត្តមមេត្តាជ្រាប និងចាត់ចែងអនុវត្តចាប់ពីថ្ងៃជូនដំណឹងនេះតាមការគួរ។

សូមឯកឧត្តមទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រអំពីខ្ញុំ។

**ប្រធានលេខាធិការដ្ឋាន គ.ជ.អ.ប**

**ចម្លងជូន :**

- អង្គភាពគាំទ្រកម្មវិធី គ.ជ.អ.ប
- គម្រោង PSDD ថ្នាក់ជាតិ
- គម្រោង PSDD រាជធានី ខេត្ត សាមុី
- ឯកសារ កាលប្បវត្តិ